## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
### នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សៀវភៅណែនាំស្តីពី
# បច្ចេកទេសចិញ្ចឹមក្រួច



**រៀបចំដោយ:**
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
សហការជាមួយ នាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

ឧបត្ថម្ភការបោះពុម្ពដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បោះពុម្ពឆ្នាំ២០២១



# សៀវភៅណែនាំ

## ស្តីពី

# បច្ចេកទេសចិញ្ចឹមក្រួច


## រៀបចំដោយ

## នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សហការជាមួយ

## នាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ



បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ឧបត្ថម្ភការបោះពុម្ពដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



រក្សាសិទ្ធិដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




# សមាសភាពចូលរួមចំណែកផលិតសៀវភៅណែនាំ ស្តីពីបច្ចេកទេសចិញ្ចឹមក្រួច

## I. ទីប្រឹក្សាផ្តល់យោបល់:

១. ឯកឧត្តម **តាន់ ផាន់ណារ៉ា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

២. បណ្ឌិត **ម៉ៅ មិនា** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## II. អ្នករៀបរៀង:

១. លោក **ផាន ទូច** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## III. អ្នកស្រាវជ្រាវ:

ក្រុមការងារនាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។

## IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

១. បណ្ឌិត **ហាយ ប្រមូល** នាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

២. លោក **ស៊ុន ប៉ោ** នាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

៣. លោក **ហុខ ទ្រី** នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។





# មាតិកា

ទំព័រ


I. **សេចក្តីផ្តើម**........................................ ០១

II. **ស្ថានភាពទូទៅ**........................................ ០១

III. **បច្ចេកទេសចិញ្ចឹម**........................................ ០២

១. ពូជ........................................ ០២

១.១ ចំណាត់ថ្នាក់ពូជ........................................ ០៣

២. ការរៀបចំទ្រុង........................................ ០៩

២.១ លក្ខណៈទ្រុង........................................ ០៩

២.១.១ ទ្រុងសម្រាប់មេពង........................................ ០៩

២.១.២ ទ្រុងសម្រាប់ក្រួចសាច់........................................ ១១

២.២ លក្ខណៈទូទៅរបស់ទ្រុងសម្រាប់ក្រួចមេ និងក្រួចសាច់ តាមគោលការធម្មជាតិ........................................ ១១

២.៣ ទ្រុងសម្រាប់កូនក្រួច........................................ ១២

៣. ចំណីសម្រាប់ក្រួច ( ចំណី និងការផ្តល់ចំណី )........................................ ១៨

៤. ការជ្រើសរើសពូជ........................................ ២១

៤.១. ការបង្កាត់ពូជ........................................ ២៣

៤.២. ការភ្ញាស់ស៊ុត........................................ ២៤

៥. ការកម្តៅកូនបក្សី........................................ ២៥

៥.១. ការថែរក្សា ឬអនុបាលកូនបក្សី........................................ ២៦

៥.២. ការជ្រើសភេទ និងការកាត់ចំពុះ........................................ ២៧

IV. **ជំងឺ និងវិធានការ ការពារ ព្យាបាល**........................................ ២៨

១. ជំងឺញ៉ូវកាស........................................ ២៨

២. ជំងឺរលាកពោះវៀន........................................ ២៩

៣. ជំងឺផ្តាសាយ........................................ ៣០

៤. ជំងឺ (Coccidiosis)........................................ ៣០

៥. ជំងឺអុត........................................ ៣១

៦. ជំងឺរលាកបំពង់ខ្យល់........................................ ៣១

៧. ជំងឺបណ្តាលពីព្រូន........................................ ៣១

V. **ការប្រមូលផល**........................................ ៣២






# បច្ចេកទេសចិញ្ចឹមក្រួច

## I. សេចក្ដីផ្ដើម៖

មុខរបរចិញ្ចឹមក្រួចមិនមែនជារបរថ្មីសម្រាប់ប្រជាកសិករយើងនោះទេ ព្រោះមានបងប្អូនប្រជាកសិករមួយចំនួន បានចាប់មុខរបរនេះតាំងពីយូរលង់ណាស់មកហើយ។ ប៉ុន្តែភាគរយនៃអ្នកចិញ្ចឹម ដែលទទួលបានជោគជ័យ នៅមានចំនួនតិច ឧបសគ្គទាំងនេះ គឺបណ្ដាលមកពីកត្តាជាច្រើនមានដូចជា កសិករមិនមានទុន មានចំនួនក្រួចចិញ្ចឹមតិច មិនសមល្មមនឹងអាចលក់បានចំណេញ មិនមានលទ្ធភាពពង្រីកការចិញ្ចឹមឱ្យបានធំជាងមុន មិនបានស្វាសស្វែងរកទីផ្សារជាមុន រងចាំតែគេមកទិញដល់ទីកន្លែង មិនមានចំណីឱ្យក្រួចស៊ីគ្រប់គ្រាន់ មិនមានពេលវេលាដើម្បីថែរក្សាក្រួចដែលខ្លួនចិញ្ចឹមឱ្យបានល្អ និងមិនមានបច្ចេកទេសក្នុងការចិញ្ចឹមឱ្យបានត្រឹមត្រូវ ដែលនាំឱ្យមុខរបរមួយនេះមិនអាចទទួលបានលទ្ធផលស្របតាមការរំពឹងទុក ដែលនេះជាដើមចមមួយចំនួន ដែលប្រជាកសិករគួរមានការពិចារណាឱ្យបានស៊ីជម្រៅ មុនពេលចាប់ផ្ដើមចិញ្ចឹម ព្រោះនេះ ជាបញ្ហាដែលយើងជាអ្នកចិញ្ចឹម ត្រូវប្រឈមជាមួយ។

ដើម្បីចូលរួមជួយជំរុញ ឱ្យមានការចិញ្ចឹមក្រួច កាន់តែមានសកម្មភាពផុសផល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយនាយកដ្ឋានផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានរៀបចំចងក្រងកូនសៀវភៅណែនាំស្ដីពីបច្ចេកទេសចិញ្ចឹមក្រួច នេះឡើងដើម្បីជាជំនួយជាចំណេះដឹងបន្ថែម ដល់បងប្អូនប្រជាកសិករដែលកំពុងប្រកបមុខរបរខាងលើឱ្យទទួលបានជោគជ័យ។

## II. ស្ថានភាពទូទៅ៖

ក្រួចត្រូវការទីកន្លែងតូច យើងមិនចាំបាច់ត្រូវមានទីធ្លាធំទូលាយ ដូចជាមាន់ទាឡើយ ទីធ្លាត្រឹមតែមួយម៉ែត្រក្រឡា ក៏អាចដាក់ក្រួចចិញ្ចឹមបានចំនួន ១០០ ក្បាល

ផងដែរ។ ដូច្នេះ យើងត្រូវជ្រើសរើសទីកន្លែងណាមួយ ដែលសមស្របបំផុត នៅក្នុងបរិវេណដីរបស់យើង ដូចជានៅចំកន្លែងទួល ស្រឡះ មានខ្យល់ចេញចូលបានល្អ មានពន្លឺថ្ងៃចូលដល់ និងមានប្រភពទឹកស្អាតសម្រាប់ផ្គត់ផ្គង់ឱ្យវា ។ ទំហំដីដែលយើងត្រូវការ ក៏អាស្រ័យទៅនឹងចំនួនក្រួចដែលយើងត្រៀមចិញ្ចឹម បើយើងមានបំណងចិញ្ចឹមក្នុងទ្រង់ទ្រាយធំ ចាំបាច់ត្រូវមានទីកន្លែងឱ្យសមាត្រទៅនឹងចំនួនក្រួចត្រូវដាក់ចិញ្ចឹម។

បើសិនជាយើងត្រៀមចិញ្ចឹមដើម្បីផ្គត់ផ្គង់សាច់សម្រាប់បរិភោគក្នុងគ្រួសារនិងលក់ចែកចាយឱ្យអ្នកក្បែរខាងក្នុងភូមិទេនោះ យើងមិនចាំបាច់ ត្រូវមានទីធ្លាធំពេកនោះទេ ត្រឹមតែ៣ម៉ែត្រគុណ និងប្រាំម៉ែត្រ គឺល្មមគ្រប់គ្រាន់សម្រាប់ចិញ្ចឹមក្រួចបានជាង ១០០០ ក្បាលដែរ។

សម្រាប់ទីផ្សារក្រួចក្នុងប្រទេសកម្ពុជា ក្នុងពេលបច្ចុប្បន្នពងក្រួចមួយគ្រាប់អាចលក់បានពី ២០០ ទៅ ៣០០ រៀល ក្រួចសាច់ ធ្វើរួចអាចលក់បានតម្លៃ ២៣០០ ទៅ ២៥០០ រៀល កូនក្រួចអាយុ១៥ថ្ងៃ អាចលក់បានម្លៃ ១៣០០ ទៅ ១៥០០ រៀល ក្នុងមួយក្បាលសម្រាប់អ្នកទិញទៅចិញ្ចឹម មេក្រួចហៀបពងអាយុ ៧ សប្តាហ៍អាចលក់បានតម្លៃ ២៥០០ ទៅ ៣០០០ រៀលក្នុងមួយក្បាល ។

## III. បច្ចេកទេសចិញ្ចឹម៖

### ១. ពូជ៖

ពូជសត្វក្រួចត្រូវបានបង្កាត់ក្នុងរយៈពេលជាង ១០០ ឆ្នាំកន្លងមក។ ទីមួយត្រូវបានគេចាត់ចែងសត្វក្រួចពីព្រៃធម្មតា។ បន្ទាប់មកមនុស្សបានចាប់ផ្តើមកែលម្អគុណភាពដែលពួកគេត្រូវការ។ លទ្ធផលគឺបសុបក្សីដែលមានផលិតភាពដែលអ្នកអាចទទួលបានសាច់ និងស៊ុត។ ទិសដៅត្រូវបានអភិវឌ្ឍដាច់ដោយឡែកពីគ្នាពីព្រោះសត្វក្រួចមិនត្រឹមតែមានប្រយោជន៍ប៉ុណ្ណោះទេថែមទាំងមានសម្រស់ស្អាតទៀតផង។

ជាទូទៅពូជសាច់គឺធ្ងន់ជាង ជាមធ្យមសត្វក្រួចមួយអាចផ្តល់ស៊ុតចន្លោះពី ២៥០ ទៅ ៣៥០ គ្រាប់ក្នុងមួយឆ្នាំ។ ពូជក្រួចខ្លះអាចមានទម្ងន់ចន្លោះពី ១២០-១៦០ ក្រាម ហើយពូជខ្លះទៀតអាចមានទម្ងន់ពី ២៥០ ទៅ ៣០០ ក្រាម។ ជាធម្មតាក្រួចញី

មានទម្ងន់ធ្ងន់ជាងឈ្មោល ១៥ ភាគរយ។

**ពូជក្រួចសំខាន់ៗរួមមាន:** ពូជក្រួចជប៉ុន (Coturnix) ពូជអង់គ្លេស (អង់គ្លេស ស និងខ្មៅ) បុប៉វ៉ាយ (Bobwhite) ពូជអូស្រ្តាលី (brown quail, King quail) ពូជក្រួចផារ៉ូ (Pharaoh) ពូជវីជីនញ៉ា (Virginia) កាលីហ្វ័រនីញ៉ា (California) ពូជក្រួចចិន ពូជក្រួចមាសម៉ាន់ជូ ពូជអ៊ីស្តូនីញ៉ា (Estonian) ពូជម៉ាប៊ើល (Marble) ពូជធុចសេដូ (Tuxedo) ពូជក្រួចហុងគ្រី ។ល។

### ១.១ ចំណាត់ថ្នាក់ពូជ:

យើងអាចបែងចែកពូជក្រួចសំខាន់ៗជា៤ ប្រភេទគឺ៖

- ពូជស៊ុត
- ពូជសាច់
- ពូជស៊ុត និងពូជសាច់
- ពូជចិញ្ចឹមលម្អ

ពូជក្រួចដែលកំពុងពេញនិយមចិញ្ចឹមក្នុងព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃគឺពូជក្រួចជប៉ុន ឬ Coturnix Quail និងពូជក្រួចអូស្រ្តាលី (Brown quail)។

#### ពូជក្រួចជប៉ុន:

ពូជក្រួចរបស់ជប៉ុនគឺជាពូជផ្តល់ស៊ុតដ៏ល្បីល្បាញបំផុតមួយទោះបីជាពូជចិញ្ចឹមយកសាច់ក៏ត្រូវបានបង្កើតឡើងនាពេលថ្មីៗនេះក៏ដោយ។

ពូជជប៉ុនមានទំហំធំ (ប្រវែងរាងកាយ ១៦-១៧ ស.ម) មានពណ៌ត្នោត - ប្រផេះស្តង់ដារ។ ពូជនេះ មានលក្ខណៈផលិតកម្មដូចខាងក្រោម៖

- ទម្ងន់ក្រួចផ្តល់សាច់ ២០០-២៥០ ក្រាម ក្រួចផ្តល់ស៊ុត ១៥០-១៨០ ក្រាម
- ចំនួនស៊ុតប្រចាំឆ្នាំ ៣០០ គ្រាប់ និងអាចច្រើនជាងនេះ
- ទម្ងន់ស៊ុត ១០-១២ ក្រាម
- អាយុនៃការចាប់ផ្តើមផ្តល់ស៊ុតគឺ ៤៥-៥០ ថ្ងៃ។




ពូជក្រួចជប៉ុន

ក្រួចឈ្មោលមានដើមទ្រូង និងបំពង់កពណ៌ទឹកក្រូច ញីមានដើមទ្រូងពណ៌សថ្លា។ អាយុកាលជាមធ្យមគឺ ២-៥ ឆ្នាំ អាស្រ័យលើសុខភាពរបស់ពួកគេ និងលក្ខខណ្ឌនៃការចិញ្ចឹម។

ពូជសាច់ត្រូវបានគេប្រើជាញីកញ្ជាប់ដើម្បីផលិតកូនកាត់ (ក្រួចសាច់ broiler) នៅពេលបង្កាត់ពូជបក្សីដើម្បីជាប្រយោជន៍ដល់ផលិតផលសាច់ ចំណុចសំខាន់គឺរបបអាហារពិសេសសម្រាប់ការបំបៅកូន។

សាច់ក្រួចត្រូវបានកំណត់ដោយកាឡូរីទាប និងកូលេស្តេរ៉ុលទាបបំផុតហើយក៏ជួយពង្រឹងប្រព័ន្ធភាពស៊ាំផងដែរ។

**ពូជក្រួចអូស្ត្រាលី (ពូជពណ៌ត្នោត):**

កសិករខ្លះគាត់ជ្រើសរើសពូជអូស្ត្រាលីយកមកចិញ្ចឹម ព្រោះវាស៊ាំនឹងអាកាសធាតុស្រុកយើង ហើយមានរូបរាងធំ ត្រឹមតែ ៣ក្បាលមានទម្ងន់ ១គីឡូក្រាម (ធៀបនឹងពូជជប៉ុន ៤ក្បាលបាន ១គីឡូក្រាម) វាជាពូជដែលលូតលាស់លឿន ហើយឆាប់ពេញវ័យ។ អ្នកចិញ្ចឹមត្រូវឱ្យចំណីវាស៊ីគ្រប់គ្រាន់ មានទ្រុងសមស្របនោះវានឹងធំធាត់ល្អឆាប់ហុចផល ពោលគឺចិញ្ចឹមតែ៣៥ថ្ងៃ អាចចាប់លក់សាច់បានហើយ តែបើចង់ចិញ្ចឹមទុកយកពងមកភ្ញាស់យកកូនលក់បន្តត្រូវចិញ្ចឹមដល់ ៤៥ ថ្ងៃ ដោយក្រួចមួយក្បាលវាពងបានចំនួន ២៤០ ទៅ ២៥០ ពងក្នុងមួយឆ្នាំ។





ពូជក្រួចអូស្ត្រាលី

**ពូជក្រួចចិន** ( Chinese painted quail ) :

ពូជក្រួចចិនក៏ត្រូវបានបង្កាត់សម្រាប់លម្អផងដែរ។ ជម្រករបស់វាគឺប្រទេសចិន អាស៊ីខាងត្បូងនិងអាស៊ីខាងកើត អូស្ត្រាលី។ សព្វថ្ងៃបក្សីសម្រាប់លម្អត្រូវបាននាំយកទៅប្រទេសជាច្រើនទៀត។ ពួកវាជាពូជតូចបំផុតនៃពូជសត្វក្រួចទាំងអស់ដែលមាន។ ពណ៌របស់ពួកវាគួរឱ្យចាប់អារម្មណ៍ណាស់ ស្រដៀងនឹងសត្វព្រៃ (pheasant)។ ខាងក្រោមនេះជាការពិពណ៌នាអំពីពូជក្រួចនេះ៖

- ចំពុះគឺខ្មៅ ជើងពណ៌ទឹកក្រូចមានពណ៌លឿង
- ថ្ពាល់ ថ្ងាស កនិងផ្នែកសងខាងពណ៌ប្រផេះលាយខៀវ
- កញ្ចឹងកនិងតំបន់ក្រោមចំពុះគឺខ្មៅ ជាមួយនឹងឆ្នូតពណ៌សរាងដូចចំណិតព្រះចន្ទ
- ឆ្នូតពណ៌ស ២ បន្ថែមទៀតចេញពីចំពុះដល់ថ្ពាល់
- ផ្នែកខាងក្រោយមានពណ៌ត្នោតមានចំណុចខ្មៅ
- ពោះពណ៌តដ្ឋ

ក្រួចញីមានរាងកាយពណ៌ត្នោតខ្មៅនៅពីលើ និងមានពណ៌ត្នោតខ្ចីនៅខាងក្រោម។ លំនាំនៅលើក្បាលនិងកគឺដូចគ្នានឹងក្រួចឈ្មោលដែរ។ វាចាំបាច់ក្នុងការថែរក្សាពូជក្រួចចិនជាក្រុមដែលមានឈ្មោល ១ និងញីពី ២-៤ ។ ឈ្មោលយកចិត្តទុកដាក់ខ្លាំងចំពោះញីរបស់ពួកវា។ ពួកវានឹងមិនដែលស៊ីរហូតដល់ឆ្អែតទេ។ ប្រសិនបើសត្វក្រួចរស់នៅក្នុងកសិដ្ឋានចិញ្ចឹមសត្វ ពួកវាអាចញាស់ពងដោយខ្លួនឯង។ កូនក្រួចធំឡើងក្នុងរយៈពេលដ៏ខ្លី និងពេញវ័យក្នុងរយៈពេល៣សប្តាហ៍។




ពូជក្រួចចិន

**ពូជក្រួចកាលីហ្វរនីញ៉ា** (California quail)៖

ក្រួចកាលីហ្វរញ៉ាគឺជាសត្វស្លាបដែលតុបតែង។ ពូជនេះមានបីប្រភេទក្នុងធម្មជាតិ។ នៅអាមេរិកសត្វបក្សីនេះត្រូវបានបង្កាត់ជាយូរមកហើយ។ នៅអឺរ៉ុបពួកវាចាប់ផ្តើមលេចឡើងតែក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ខាងក្រោមនេះជាការពិពណ៌នាអំពីពូជក្រួចកាលីហ្វរញ៉ា៖

- ក្បាលមានទំហំតូច ដោយមានឆ្នូតខ្មៅ រោម ៤-៧ កោងទៅមុខ
- ចំពុះខ្លី រឹងមាំ និងកោងបន្តិច
- រាងកាយគឺ ធំធាត់ បង្រួមសងខាង
- ជើងមានប្រវែងមធ្យម
- ស្លាបខ្លី និងមូលនៅចុងស្លាបទីបួន និងស្លាបទីប្រាំវែង
- កន្ទុយខ្លី បញ្ចេញសម្លេងបន្តិច ពេលបោះជំហាន
- ថ្ងាសមានពណ៌សជាមួយពណ៌លឿងមានឆ្នូតពណ៌សតូច នៅលើកំពូលដែលទៅខាងក្រោយក្បាល
- មានមុខជាមួយឆ្នូតពណ៌ខ្មៅដែលលាតសន្ធឹងពីសិរ
- ពីថ្ពាល់នៅតាមកញ្ចឹងកនិងចង្កាមានឆ្នូតពណ៌សរាងដូចព្រះច័ន្ទបញ្ច្រាស
- ក និងកញ្ចឹងកមានពណ៌ប្រផេះ-ខៀវខ្ចីនៅលើកំពូលស្លាបនីមួយៗមានដូចជាទងពណ៌ខ្មៅ ឆ្នូតភ្លឺ និងស្នាមចុចតូចៗនៅចុង

- ផ្នែកខាងក្រោយគឺពណ៌អូលីវត្នោត
- កពក និងទ្រូងមានពណ៌ប្រផេះ-ពណ៌ខៀវខាងលើ
- នៅលើពោះមានលំនាំស្លាបពណ៌ត្នោតដែលមានព្រំដែនខ្មៅស្រដៀងនឹងស្រកាត្រី
- ជើងមានពណ៌ប្រផេះ កម្ពស់របស់ពួកវាគឺ ២៣-២៥ ស.ម
- ពណ៌របស់ក្រួចញីគឺមិនសូវភ្លឺរលោងទេ ពណ៌ត្នោត - ប្រផេះ ជាទូទៅមិនមានឆ្នូតខ្មៅ និងសនៅលើក្បាលទេ ពូជក្រួចកាលីហ្វរញ៉ាពងពី ៩-១៥ គ្រាប់។ សូម្បីតែនៅផ្ទះក៏ដោយពួកវារស់នៅជាគូមិនមែនជាក្រុមទេ។ សម្រាប់គូនីមួយៗនេះ គួរតែបង្កើតទ្រុងដាច់ដោយឡែកមួយ។ ដូចជាសត្វក្រួចផ្សាំងដទៃទៀតដែរពូជក្រួចកាលីហ្វរញ៉ាបានបាត់បង់នូវការក្រាបពងរបស់ពួកវា ដូច្នេះកូនក្រួចត្រូវតែចិញ្ចឹមនៅក្នុងទូរភ្ញាស់។

 

*ពូជក្រួចកាលីហ្វរញ៉ា*

### ពូជក្រួចអង់គ្លេសពណ៌ខ្មៅ:

ក្រួចអង់គ្លេសពណ៌ខ្មៅក៏ត្រូវបានបង្កាត់ឡើងដោយផ្អែកលើពូជក្រួចជប៉ុនដែរ។ ការបង្កាត់ពូជវាមិនមានប្រជាប្រិយភាព ដូចការកើនឡើងក្រួចពណ៌សទេ។ ការពិតគឺថាគ្រោងឆ្អឹងរបស់បក្សីនេះខ្មៅហើយមិនមែនគ្រប់គ្នាចូលចិត្តពណ៌នេះទេ។ រោមនៃប្រភេទសត្វក្រួចនេះមានចាប់ពីពណ៌ត្នោតខ្មៅទៅខ្មៅ។ លក្ខណៈផលិតផលគឺខ្ពស់

ជាងសត្វក្រួចពណ៌ស៖

- ទម្ងន់ក្រួចញីអតិបរមា ២០០ ក្រាម និងក្រួចឈ្មោល ១៧០ ក្រាម
- ចំនួនស៊ុតប្រចាំឆ្នាំ ២៨០ គ្រាប់
- ស៊ុតមួយមានទម្ងន់ ១០ - ១១ ក្រាម

មានពូជក្រួចផ្ដល់ពង និងពូជក្រួចខ្មៅ។ ពួកវាមានទម្ងន់២០០-២១០ ក្រាម ប៉ុន្តែការផលិតស៊ុតទាបប្រហែល ១៦០-១៨០ គ្រាប់ក្នុងមួយឆ្នាំ។ សត្វក្រួចប្រភេទនេះត្រូវបានបង្កាត់ជាញឹកញាប់សម្រាប់ការចូលចិត្តផ្ទាល់ខ្លួននិងសម្រាប់ការបរិភោគនៅតាមផ្ទះ។




ក្រួចអង់គ្លេសពណ៌ខ្មៅ




ក្រួចអង់គ្លេសពណ៌ស

## ២. ការរៀបចំទ្រុងៈ

ទ្រុងដែលប្រើសម្រាប់ការចិញ្ចឹមក្រួច ត្រូវមានខ្យល់អាកាសចេញចូលល្អ សភាពខាងក្នុងទ្រុង មិនត្រូវងងឹត ឬភ្លឺពេកទេ លក្ខណៈរបស់ទ្រុងត្រូវសាងសង់ដំបូលជារៀងត្រីកោណពីរថ្នាក់មានលក្ខណៈល្អជាង ព្រោះអាចធ្វើឱ្យមានខ្យល់អាកាសចេញចូលបានស្រួល និងមានពន្លឺគ្រប់គ្រាន់។

ផ្ទៃទ្រុងអាចធ្វើអំពីស៊ីម៉ងត៍ ដើម្បីងាយស្រួលក្នុងការធ្វើអនាម័យ ចំណែកដំបូលអាចប្រក់ស័ង្កសី ឬស្បូវ តែស្បូវអាយុកាលខ្លីប្រើមិនបានយូរ ហើយពិដានទ្រុងគួរមានកម្ពស់ឱ្យសមល្មម ដើម្បីសន្សំផ្ទៃទ្រុង ដើម្បីដាក់ក្រួចបានច្រើនថ្នាក់ មិនត្រូវឱ្យទើសគ្នា និងទុកឱ្យមានខ្យល់អាកាសចេញចូលបានគ្រប់គ្រាន់។

ផ្ទៃទ្រុងត្រូវមានពន្លឺគ្រប់គ្រាន់ ដើម្បីឱ្យក្រួចស៊ីចំណី និងផឹកទឹកបានគ្រប់ពេល ដោយពេលពាក់កណ្តាលយប់ អ្នកចិញ្ចឹមត្រូវបើកភ្លើងបន្ថែមរហូត គឺដើម្បីជួយជំរុញឱ្យក្រួចផ្តល់ស៊ុតបានកាន់តែច្រើន។

### ២.១ លក្ខណៈទ្រុង:

ជាទូទៅទ្រុងត្រូវមានសភាពស្ងួត និងមានកម្តៅ (២៨-៣៧ អង្សាសេ ) មានខ្យល់ចេញចូលបានល្អ និងមានពន្លឺគ្រប់គ្រាន់។ លក្ខណៈរបស់ទ្រុងចែកចេញជាៈទ្រុងសម្រាប់មេពង ទ្រុងសម្រាប់ក្រួចយកសាច់ និងទ្រុងសម្រាប់កូនក្រួច។

### ២.១.១ ទ្រុងសម្រាប់មេពង:

ទ្រុងសម្រាប់មេពងអាចសង់បានពីររបៀបគឺៈ

ទ្រុងសម្រាប់មេពងជាលក្ខណៈផ្ទាល់ដីៈ ក្នុងករណីមានមេក្រួចច្រើនយើងអាចដាក់ទ្រុងផ្ទាល់ដីក៏បាន ប៉ុន្តែទ្រុងផ្ទាល់ដីមេក្រួចអាចមានចលនាច្រើន ដែលងាយនឹងបង្កភាពងាយស្រួលក្នុងការធ្វើឱ្យពងបែក ហើយក្នុងចន្លោះពេល ៣ ទៅ ៥ ថ្ងៃ ត្រូវបោសលាមកម្តង

- ☞ ត្រូវកាត់ចំបើងខ្លី ឬស្លឹកឈើស្ងួតក្រាលបាតទ្រុង
- ☞ ត្រូវក្រាលអង្កាមបាតទ្រុងឱ្យក្រាស់

☛ សីតុណ្ហភាពនៅក្នុងទ្រុងត្រូវមានចន្លោះពី២៨-៣២ អង្សាសេ





ទ្រុងមេពងជាលក្ខណៈផ្ទាល់ដី

ទ្រុងសម្រាប់មេពងជាលក្ខណៈសំណាញ់ផុតពីដីៈ ត្រូវធ្វើទ្រុងសំណាញ់ ឬអំពីឫស្សី ឱ្យផុតពីដីយ៉ាងតិច០.៥-០.៨ ម៉ែត្រ ដើម្បីងាយស្រួលបោសសំអាតលាមកបាតទ្រុង។





ទ្រុងមេពងជាលក្ខណៈសំណាញ់ផុតពីដី

ទំហំទ្រុងៈ បណ្តោយ ២.៧ x ទទឹង ១.៧ម៉ែត្រ សម្រាប់ក្រួចមេចំនួន ១៨០-២០០ ក្បាល (១ម៉ែត្រការ៉េអាចដាក់ក្រួចបានប្រហែល៣៥-៤០ក្បាល) ដើម្បីឱ្យក្រួចងាយស្រួលក្នុងការស៊ីចំណី និងងាយស្រួលក្នុងការដើរ ដីបាតទ្រុងត្រូវមានសភាពរាបស្មើល្អ ងាយស្រួលក្នុងការរើសពង។

■☞ ត្រូវបោសសម្អាតទ្រុងក្នុងមួយថ្ងៃយ៉ាងតិច១ដង (ធ្វើទ្រុងសំណាញ់មានសភាពងាយស្រួលជាងទ្រុងផ្ទាល់ដី)។

### ២.១.២ ទ្រុងសម្រាប់ក្រួចសាច់:

ទ្រុងសម្រាប់ក្រួចសាច់ត្រូវធ្វើរោងការពារកម្ដៅ ភ្លៀង និងខ្យល់ នៅបរិវេណទ្រុងត្រូវពាត់សំណាញ់ឱ្យជិតល្អ ។

■☞ ទ្រុងទំហំ ៦ ម៉ែត្រការ៉េអាចដាក់ក្រួចបាន៣០០ក្បាល

■☞ កម្ដៅធម្មតាពី១៥-២១ អង្សាសេ (អាយុពី២៨-៣២ថ្ងៃឡើងទៅ)

■☞ ត្រូវក្រាលអង្កាមស្តើងៗ ដើម្បីងាយស្រួលក្នុងការបោសសម្អាតលាមក (៣-៥ថ្ងៃ បោសលាមកម្ដងហើយមើលល្បាយអង្កាម និងលាមកស្មើគ្នាឬអត់)

■☞ ត្រូវរុំសំពត់កៅស៊ូ ឬក្រណាត់ជុំវិញទ្រុង (ការពារភ្លៀង ខ្យល់ និងជួយហុំកម្ដៅបន្ថែមនៅពេលយប់)

### ២.២ លក្ខណៈទូទៅរបស់ទ្រុងសម្រាប់ក្រួចមេ និងក្រួចសាច់ តាមគោលការធម្មជាតិ:

នៅពេលក្រួចមានអាយុ២៥ថ្ងៃឡើងទៅ នៅរដូវក្ដៅយើងអាចធ្វើទ្រុងផ្សំ និងធម្មជាតិបានដូចជា:

■☞ រុំសំណាញ់ជុំវិញបរិវេណទ្រុង

■☞ ធ្វើទ្រុងហប់មួយទុកឱ្យវាដេក

■☞ ផ្ដល់កម្ដៅឱ្យបានគ្រប់គ្រាន់នៅពេលយប់





*ថែរក្សាកូនក្រួចឱ្យក្ដៅជាមួយចង្កៀង ឬអំពូលកម្ដៅ*





*ការកម្តៅកូនក្រួចដោយអំពូលភ្លើង*

## ២.៣ ទ្រុងសម្រាប់កូនក្រួច :

ទ្រុងសម្រាប់កូនញាស់ពី១-៥ថ្ងៃៈ កូនក្រួចត្រូវការកម្តៅចន្លោះពី ៣៥-៣៧ អង្សាសេ ត្រូវមានខ្យល់ចេញចូលស្រួល

- ត្រូវហ៊ុំក្រណាតឱ្យជិតជុំវិញបរិវេណទាំងមូល
- ត្រូវក្រាលអង្កាមឱ្យក្រាស់ហើយស្មើល្អ
- ក្រោយពីញាស់បាន៦-១២ម៉ោងត្រូវផ្តល់ទឹក និងចំណីភ្លាម
- ទំហំទ្រុង៧ម៉ែត្រ អាចដាក់កូនក្រួចបានប្រហែល២០០០ក្បាល
- ត្រូវមានកូនចង្រ្កានធ្យូង ឬអំពូលភ្លើងកម្តៅពេញ២៤ម៉ោង
- មិនត្រូវឱ្យកូនក្រួចដួលចូលក្នុងធុងទឹកឡើយ
- ចំណី និងទឹកត្រូវមានជាប់ជាប្រចាំ
- ស្នូកចំណីត្រូវវែង ដោយមានលួសសំណាញ់ក្រឡាល្អិតពីលើ ដើម្បីកុំឱ្យកូនក្រួចដួល ឬធ្លាក់ចូល
- ថែរក្សាក្រួចដោយផ្តល់កម្តៅជាមួយចង្កៀង ឬអំពូលកម្តៅ
  - សប្តាហ៍ទី១: ៣៥ - ៣៦ អង្សាសេ ($^0$C)
  - សប្តាហ៍ទី២: ៣២ - ៣៤ អង្សាសេ ($^0$C)
  - សប្តាហ៍ទី៣: ២៩ - ៣០ អង្សាសេ ($^0$C)

- សប្តាហ៍ទី៤: ២៦.៦ - ២៨ អង្សាសេ (⁰C)
- សប្តាហ៍ទី៥: ២៤ - ២៥ អង្សាសេ (⁰C)
- សប្តាហ៍ទី៦: ផ្តល់អំពូលកម្តៅនៅខាងក្រៅប្រសិនបើសត្វក្រួចសុំាទៅនឹងអាកាសធាតុថ្មី ធ្វើឱ្យក្រួចមានភាពងាយស្រួលក្នុងការរស់នៅក្នុងទ្រុងខាងក្រៅ។

☞ ទ្រុងសម្រាប់កូនញាស់ពី៥-១០ថ្ងៃ: ចំណី ទឹក កម្តៅ និងពន្លឺត្រូវមានជាប់រហូត




ទ្រុងសម្រាប់កូនញាស់ពី១-៥ថ្ងៃ

- ☞ សីតុណ្ហភាពក្នុងទ្រុងត្រូវមានចាប់ពី៣៣-៣៥អង្សាសេ
- ☞ ទ្រុងចាំបាច់ត្រូវស្ងួតមិនដក់ទឹក
- ☞ ស្នូកចំណីត្រូវជាថាសស្តើងហើយមិនអាចខ្ចាយចំណីចេញបាន
- ☞ ស្នូកទឹកត្រូវដាក់ដោយប្រុងប្រយ័ត្នព្រោះកូនក្រួចអាចធ្លាក់ចូលបាន
- ☞ ផ្ទៃអង្កាមបាតទ្រុងត្រូវលុញឱ្យស្មើគ្នា
- ☞ រៀបដុំឥដ្ឋ៤ដុំ ហើយដាក់ក្អមធ្យូងកម្តៅបន្ថែម
- ☞ ចងទែម៉ូម៉ែត្រដើម្បីជួយពិនិត្យកម្តៅ
- ☞ ស្នូកទឹកត្រូវចោះគម្របចំកណ្តាលទុកប្រលោះទឹកល្មម ដើម្បីឱ្យកូនក្រួច



ងាយស្រួលឱនក្បាលផឹកទឹក និងមិនដួលទទឹករោម (បណ្តាលឱ្យខ្សោយ ឬស្លាប់បាន)

☛ នៅពេលផ្ទេរកូនក្រួចពីទ្រុងដែលមានអាយុ ៥-៧ ថ្ងៃ ត្រូវផ្តល់កម្តៅភ្លាម (ក្នុងករណីដែលសីតុណ្ហភាពខាងក្រៅត្រជាក់)

## ៣. ចំណីសម្រាប់ក្រួច (ចំណី និងការផ្តល់ចំណី)៖

សត្វក្រួចគឺជាសត្វស្លាបព្រៃដូច្នេះ ពួកវាត្រូវការប្រូតេអ៊ីនច្រើនជាងមាន់ដើម្បីធ្វើឱ្យមានសុខភាពល្អ។ ទោះបីជាយ៉ាងណាក៏ដោយអ្នកអាចផ្តល់ចំណីឱ្យក្រួចនូវចំណីមាន់ដែលមិនមានលាយថ្នាំបណ្តោះអាសន្នក៏បាន ព្រោះពួកវាពិតជាត្រូវការអាហារដែលមានជាតិប្រូតេអ៊ីនខ្ពស់។

សត្វក្រួចមិនសូវស៊ីចំណីច្រើនពេកទេ។ នោះមានន័យថា ទោះបីជាមានអាហារបន្ថែមក៏ដោយ ក៏ពួកវាស៊ីនឹងផឹកតែអ្វី ដែលពួកវាត្រូវការប៉ុណ្ណោះ។ នេះជាកត្តាធ្វើឱ្យយើងងាយស្រួលក្នុងការវាស់វែង មុនផ្តល់ចំណីឱ្យពួកវាតិច ឬច្រើន។

### សារធាតុចញ្ចឹមចាំបាច់:

| បរិយាយ | ប្រូតេអ៊ីន % | កាលស្យូម % | ផូសស្វ័រ % | មេចូនីន % |
|---|---|---|---|---|
| ចាប់ផ្តើម (Starter) 0-6 សប្តាហ៍-Bobtail | 23.0 | 1.0 | 0.50 | 0.50 |
| ក្រួចសាច់ (Finisher Meat) -Bobtail | 19.0 | 0.90 | 0.50 | 0.40 |
| ក្រួចសាច់ (Finisher Meat) -Bobtail | 20.0 | 0.90 | 0.50 | 0.42 |
| កំពុងលូតលាស់ (បក្សីពូជ) 6-20 សប្តាហ៍-Bobtail | 18.0 | 1.0 | 0.50 | 0.40 |
| បក្សីពង 20 សប្តាហ៍+, Bobtail | 19.0 | 2.75 | 0.65 | 0.50 |
| ចាប់ផ្តើម (Starter) 0-6 សប្តាហ៍, Coturnix | 24.0 | 0.85 | 0.60 | 0.50 |





| | | | | |
|---|---|---|---|---|
| ក្រួចសាច់ (Meat Finisher) 6 សប្តាហ៍+ ដល់លក់, Coturnix | 18.0 | 0.65 | 0.50 | 0.40 |
| បក្សីពង 6 សប្តាហ៍+, Coturnix | 18.0 | 2.75 | 0.65 | 0.45 |

### ផ្តល់កាល់ស្យូម និងក្រួស (Grit) ដល់ក្រួច:

ក្រួចត្រូវការជាតិកាល់ស្យូមដើម្បីជំនួយពងល្អ។ សំបកអយស្ទ័រ (ឬសំបកខ្យងខ្មៅ) គឺជាវិធីដែលធ្វើឱ្យសត្វមានសុខភាពល្អក្នុងការផ្តល់កាល់ស្យូមដល់សត្វក្រួច។ ក្រួស (Grit) អាចត្រូវបានផ្តល់តាមរយៈដីខ្សាច់ ឬ Chicken grit។ វាជួយឱ្យសត្វក្រួចបំបែកអាហាររបស់ពួកវា។ សត្វក្រួចមិនមានធ្មេញហើយពួកវាប្រើ ក្រួសដើម្បីជួយកិនអាហារសម្រាប់ការរំលាយអាហារ។

### ចំណីក្រួចលាយតាមរូបមន្ត

| បរិយាយ | ចំណីចាប់ផ្តើម (០-៦ សប្តាហ៍) | ចំណីសម្រាប់ក្រួចកំពុងលូតលាស់ (បន្ទាប់ពី ៦ សប្តាហ៍) |
|---|---|---|
| សារធាតុផ្សំ % | | |
| ពោតក្រហម | 48.0 | 46.5 |
| ស្រូវសាឡី (Wheat) | 6.0 | 6.0 |
| កាកសណ្តែកសៀង SBM | 33.0 | 34.0 |
| ប្រេងបន្លែ | 4.0 | 4.5 |
| ម្សៅត្រី | 4.0 | 4.0 |
| ម្សៅឆ្អឹង-សាច់ | 2.5 | 2.5 |
| ឌីកាល់ស្យូម ផូសហ្វាត (DCP) | 0.5 | 0.5 |
| ថ្មកំបោរ | 1.0 | 1.0 |

| | | |
|---|---|---|
| មេចូនីន | 0.2 | 0.2 |
| លីស៊ីន | 0.1 | 0.1 |
| អំបិល | 0.4 | 0.4 |
| ព្រីមិច(វីតាមីន+សារធាតុរ៉ែ) | 0.3 | 0.3 |
| សរុប | 100 | 100 |
| ក្នុងនោះមាន៖ | | |
| ប្រូតេអ៊ីន % | 23.0 | 23.0 |
| ថាមពល (ME, kcal/kg) | 3100 | 2800 |

## ចំណីលាយតាមរូបមន្ត

| ល.រ | វត្ថុធាតុដើម | បរិមាណ គ.ក្រ |
|---|---|---|
| | | លាយចំណីសរុបៈ 50 គ.ក្រ |
| 1 | ពោតក្រហម | 24,5 |
| 2 | កន្ទក់ | 2,5 |
| 3 | កាកសណ្តែកសៀង | 19,0 |
| 4 | ម្សៅត្រី | 1,3 |
| 5 | ប្រេងឆា | 0,8 |
| 6 | អំបិល | 0,15 |
| 7 | ថ្មកំបោរ | 0,5 |
| 8 | បាសមិច 2.5% | 1,25 |

## រូបមន្តចំណីក្រួចសាច់ពី ១ ដល់ ៣៥ ថ្ងៃ

| ល.រ | វត្ថុធាតុដើម | បរិមាណ គ.ក្រ |
|---|---|---|
| 1 | បាសមិច | 1.5 |
| 2 | កាកសណ្តែកសៀង SBM (46%) | 15.0 |

| | | |
|---|---|---|
| 3 | ពោត ឬចុងអង្ករ | 31.0 |
| 4 | ម្សៅត្រី (៦០%) | 2.5 |
| | សរុប: | 50.0 |

## ក្នុងនោះអាហារូបត្ថម្ភសរុប:

| ថាមពល (តិចបំផុត) | ៣០០០ គីឡូកាល់ឡូរី/គ.ក្រ |
|---|---|
| ប្រូតេអ៊ីន (តិចបំផុត) | 22% |
| ខ្លាញ់ (តិចបំផុត) | 4% |
| ជាតិសរសៃ (តិចបំផុត) | 5% |
| កាល់ស្យូម (តិចបំផុត-ច្រើនបំផុត) | 0.8-1.2% |
| ផូស្វ័រ (តិចបំផុត) | 0.6% |
| អំបិល (តិចបំផុត-ច្រើនបំផុត) | 0.2-0.5% |
| លីស៊ីន (តិចបំផុត) | 1% |
| មេច្យូនីន + ស៊ីសស្ទីន (តិចបំផុត) | 0.8% |
| ត្រេអូនីន (តិចបំផុត) | 0.7% |
| ទ្រីបតូផាន (តិចបំផុត) | 0.2% |

## រូបមន្តចំណីក្រួចពង:

| ល.រ | វត្ថុធាតុដើម | បរិមាណ គ.ក្រ |
|---|---|---|
| 1 | បាសមិច | 1.5 |
| 2 | កាកសណ្តែកសៀង SBM (៤៦%) | 16.0 |
| 3 | ពោត ឬចុងអង្ករ | 27.5 |
| 4 | ម្សៅត្រី (៦០%) | 1.0 |
| 5 | ប្រេងបន្លែ | 0.5 |
| 6 | សំបកគ្រំ ឬថ្មកំបោរ | 3.5 |
| | សរុប: | 50 |

## ក្នុងនោះអាហារូបត្ថម្ភសរុប:

| ថាមពល (តិចបំផុត) | ២៧០០ គីឡូកាល់ឡូរី/គ.ក្រ |
|---|---|
| ប្រូតេអ៊ីន (តិចបំផុត) | 20% |
| ខ្លាញ់តិចបំផុត (តិចបំផុត) | 4% |
| ជាតិសរសៃ (តិចបំផុត) | 5% |
| កាល់ស្យូម (តិចបំផុត-ច្រើនបំផុត) | 3-4% |
| ផូសស្វ័រ (តិចបំផុត) | 0.6% |
| អំបិល (តិចបំផុត-ច្រើនបំផុត) | 0.2-0.5% |
| លីស៊ីន (តិចបំផុត) | 1% |
| មេច្យូនីន + ស៊ីសស្ទីន (តិចបំផុត) | 0.7% |
| ត្រេអូនីន (តិចបំផុត) | 0.7% |
| ទ្រីបតូផាន (តិចបំផុត) | 0.2% |

## ការលាយចំណីក្រួចតាមរូបមន្ត:

| វត្ថុធាតុដើម | ចំណីម៉ង្ហកូនក្រួច | ចំណីម៉ង្ហក្រួចកំពុងលូតលាស់ |
|---|---|---|
| | ០-៣ សប្តាហ៍ | ៤-៦ សប្តាហ៍ |
| ពោត | 27 | 31 |
| Sorghum | 15 | 14 |
| កន្ទក់ | 8 | 8 |
| នំសណ្តែកដី | 17 | 17 |
| នំគ្រាប់ផ្កាឈូករតន៍ | 12.5 | 12.5 |
| កាកសណ្តែកសៀង SBM (46%) | 8 | - |
| ម្សៅត្រី | 10 | 10 |
| ព្រីមិចសារធាតុរ៉ែ | 2.5 | 2.5 |
| ខ្សាច់គ្រួស (Shell grit) | - | 5 |
| សរុប: | 100 | 100 |

ចំណីសម្រេច:

■☞ Cៗ៤ សញ្ញារូបកុក ( ស៊ីសុទ្ធ បើមានលទ្ធភាព )

■☞ Cៗ៤ ២៥គីឡូក្រាម កន្ទក់៥គីឡូក្រាម ពោត ៥គីឡូក្រាម (ឥតមានពោតដាក់កន្ទក់សុទ្ធក៏បាន)

ចំណីក្រួចសាច់: ស្មើនឹង ១៥០ គីឡូក្រាម ចំណីកូនមាន់៥០គីឡូក្រាម ពោតក្រហម៥០ គីឡូក្រាម កន្ទក់ ៥០ គីឡូក្រាម។



ការលាយចំណី




ចំណីសម្រេច

■☞ Cៗ២ សញ្ញារូបកុក (ស៊ីសុទ្ធ បើមានលទ្ធភាព )

■☞ Cៗ២ ២៥គីឡូក្រាម កន្ទក់៥គីឡូក្រាម ពោត ៥គីឡូក្រាម (ឥតមានពោតដាក់កន្ទក់សុទ្ធក៏បាន)

ចំណីសម្រាប់កូនក្រួច: កូនក្រួចត្រូវស៊ីចំណីកូនសុទ្ធគឺ

■☞ ចំណីសម្រេច Cៗ២ សញ្ញារូបកុក ( ស៊ីមិនកំណត់ )




ចំណីសម្រេច Cៗ២



ការដាក់ចំណី

ត្រូវផ្លាស់ប្តូរចំណីពីកូនទៅមេតាមកម្មវិធី ក្រួចមេ ១០ ឱ្យស៊ី ២៥ក្រាម ក្នុងមួយថ្ងៃ សម្រាប់ក្រួចទាំង៤ប្រភេទនេះគឺស៊ីចំណីគ្មានកំណត់ ប្រសិនបើអាចធ្វើទៅបាន ។

**តារាងកម្មវិធីសម្រាប់ក្រួចក្នុងការស៊ីចំណីសម្រេច:**

| ចំណីកូនពី១-៥ថ្ងៃ | ចំណីកូនពី៥-១០ថ្ងៃ | ចំណីសាច់ | ចំណីមេ |
|---|---|---|---|
| C៣២ស៊ីមិនកំណត់ | C៣២ស៊ីមិនកំណត់ | C៣២ស៊ីមិនកំណត់ | C៣៤ស៊ីមិនកំណត់ |

លក្ខណៈពិសេសរបស់ចំណីៈ ករណីប្រើលាយចាំបាច់ត្រូវប្រើម៉េវ្យា (Bio Premix 12 ) មួយកញ្ចប់មានទម្ងន់ ១ គ.ក្រ លាយចំណីទម្ងន់ ៤០០គីឡូក្រាម



ម៉េវ្យា Bio Premix12

**ចំណាំ:**

ការផ្តល់ទឹកក្រួចមេ១០០ក្បាល គឺផ្តល់ទឹកពី៧-១០ លីត្រ( ត្រូវផ្តល់ទឹកស្អាត ) សម្អាតស្នូកទឹកជារៀងរាល់ថ្ងៃ (ក្រួចផឹកទឹកយប់ច្រើនជាងថ្ងៃ )

**បទពិសោធន៍កសិករចិញ្ចឹមក្រួចនៅប្រទេសកម្ពុជា:**

- ចំណីសម្រាប់មេក្រួចពងៈ ចំណីសរុប ១៥០ គីឡូក្រាម ក្នុងនោះ ចំណីទាពង ចំនួន ៥០គ.ក្រ ពោតក្រហម ៥០គ.ក្រ (កិនឱ្យម៉ត់) និងកន្ទក់ម៉ត់ ៥០គ.ក្រ។

យើងអាចប្រើចំណីសម្រេចៈ ២៥ គ.ក្រ ចំណីសម្រេច កន្ទក់ ៥ គ.ក្រ និងពោតក្រហម ៥ គ.ក្រ។

- ចំណីក្រួចសាច់ៈ ចំណីសរុប ១៥០ គីឡូក្រាម ក្នុងនោះចំណីកូនមាន់ ៥០ គ.ក្រ ពោតក្រហម ៥០ គ.ក្រ និងកន្ទក់ ៥០ គ.ក្រ។

យើងអាចប្រើចំណីសម្រេច៖ ២៥ គ.ក្រ ចំណីសម្រេច កន្ទក់ ៥ គ.ក្រ និងពោត ៥ គ.ក្រ។

ចំណីសម្រាប់កូនក្រួចៈ ចំណីកូនក្រួចយើងអាចឱ្យវាស៊ីចំណីកូនមាន់សុទ្ធ។ សរុប ១៥០ គីឡូក្រាម ក្នុងនោះចំណីកូនមាន់ ៥០ គ.ក្រ ពោតក្រហម ៥០ គ.ក្រ និង កន្ទក់ ៥០ គ.ក្រ។

**ចំណាំ:** យើងត្រូវចផ្លាស់ប្តូរចំណីពីកូនក្រួចទៅមេតាមកម្មវិធី មេក្រួច ១០ ក្បាលឱ្យស៊ី ២៥ក្រាម ក្នុងមួយថ្ងៃ។ សម្រាប់ក្រួចទាំងនេះគឺឱ្យស៊ីចំណីគ្មានកំណត់ ប្រសិនបើអាចធ្វើទៅបាន។

តារាងកម្មវិធីសម្រាប់ក្រួចក្នុងការស៊ីចំណីសម្រេចៈ

| កូនក្រួចពី ១-៥ថ្ងៃ | កូនក្រួចពី ៥-១០ថ្ងៃ | ក្រួចសាច់ | ក្រួចមេ |
|---|---|---|---|
| ចំណីស៊ីមិនកំណត់ | ចំណីស៊ីមិនកំណត់ (ដូចចំណីខាងដើម) | ចំណីស៊ីមិនកំណត់ (ដូចចំណីខាងដើម) | ចំណីស៊ីមិនកំណត់ (ចំណីមេក្រួច) |

**ចំណាំ:** ក្នុងការលាយចំណីផ្ទាល់ខ្លួនយើងអាចលាយ ព្រីមិច (Premix) ឬ បាសមិច (Basemix) បន្ថែម ជាទូទៅបរិមាណលាយ ២,៥% ក្នុងចំណី។

ការផ្តល់ទឹកសម្រាប់ក្រួច

ចំពោះក្រួចមេតម្រូវការទឹក ៧-១០ លីត្រ សម្រាប់ ១០០ ក្បាល។ ត្រូវផ្តល់ទឹកស្អាតជាប្រចាំសម្រាប់ក្រួច និងសំអាតស្នូកទឹកជារៀងរាល់ថ្ងៃ។

## ៤. ការជ្រើសរើសពូជៈ

ពូជក្រួចដែលគេនិយមចិញ្ចឹមជារបៀបជំនួញនៅក្នុងប្រទេសកម្ពុជា គឺមានតែពូជក្រួចជប៉ុនប៉ុណ្ណោះដែលមានបីពណ៌ៈ ពណ៌ខ្មៅលាយស ឬលាយក្រហម និងលឿង ហើយស៊ុតរបស់វាមានពណ៌ស។

ប្រភេទពូជនេះងាយស្រួលក្នុងការចិញ្ចឹមមានការលូតលាស់លឿន ឆាប់ផ្តល់ស៊ុត និងក្នុងចំនួនច្រើន ឆាប់បានប្រមូលផលព្រមទាំងមានភាពស៊ាំទៅនឹងជំងឺបានខ្ពស់ទៀតផង ។

ពេលចាប់ផ្តើមដំបូង គឺត្រូវទិញ មេ និងបាពូជ ពីអ្នកចិញ្ចឹមពីប្រភពផ្សេងៗគ្នា



ពណ៌ខ្មៅលាយស



ពណ៌ខ្មៅលាយក្រហម



ពណ៌លឿង



ពងក្រួច

ហើយភាគច្រើននាំចូលពីប្រទេសថៃ និងវៀតណាម។ ក្នុងការជ្រើសរើសពូជនេះ យើងត្រូវរើសយកកូនក្រួចណាដែលមានសភាពលក្ខណៈល្អ ដើម្បីទុកប្រើប្រាស់ជាពូជសម្រាប់ជំនាន់ក្រោយ ហើយត្រូវការពារការបង្កាត់ជាន់ឈាមគ្នា (បង្កាត់រវាងបងប្អូនគ្នា) ហេតុនេះតម្រូវឱ្យទិញក្រួចពីប្រភពផ្សេងៗទៀត ដើម្បីបង្កាត់ជាមួយពូជក្រួចដែលនៅក្នុងកសិដ្ឋានរបស់ខ្លួន ។

☞ ក្រួចបាពូជអាយុ៣០ថ្ងៃ មានតម្លៃ ៥ ទៅ ៨ បាត ក្នុងមួយក្បាលដែលគិតជាមធ្យមគឺ៨បាតក្នុងមួយក្បាល

☞ ក្រួចមេពូជអាយុ២០ថ្ងៃ មានតម្លៃ ៧ ទៅ ៩ បាត ក្នុងមួយក្បាលដែលគិតជាមធ្យមគឺ៨បាតក្នុងមួយក្បាល ។

## ៤.១. ការបង្កាត់ពូជៈ



ក្រួចឈ្មោលរោមទ្រូងមានពណ៌ត្នោតដិត ពេញវ័យមានសម្លេងរងាយខ្លាំង



ក្រួចញីរោមទ្រូងមានសប្បុរអុចតូចៗ ចូលចិត្តសភាពស្ងៀមស្ងាត់

ក្រួចចាប់ផ្ដើមបង្កាត់ពូជ នៅពេលអាយុបាន៤៥-១២០ ថ្ងៃ ឬជាមធ្យមប្រមាណ ៦០ ថ្ងៃ គេបង្កាត់ពូជពួកវា ដោយការយកក្រួចឈ្មោលដាក់ក្នុងទ្រុងរួមគ្នាជាមួយក្រួចញី ព្រមទាំងធ្វើការបែងចែករវាងភេទឈ្មោល និង ភេទញី តាមសមាមាត្រឈ្មោលមួយមេបី ប្រសិនបើអត្រាសត្វញីខ្ពស់ពេកនោះ ធ្វើឱ្យអត្រាបង្កកំណើតរបស់ស៊ុត (កំណកូនក្នុងស៊ុត) មានកម្រិតទាប ។ រួចយើងចាប់ផ្ដើមប្រមូលស៊ុតទាំងនោះ ដើម្បីជៀសវាងកុំឱ្យស៊ុតកខ្វក់ ។

ស៊ុតក្រួចដែលមានអត្រាបង្កកំណើត គឺប្រភេទស៊ុតដែលប្រមូលមកពីមេបា



ក្រួចឈ្មោលមានស្មែម



ក្រួចញី

មានអាយុពី ៧០-១២០ថ្ងៃ ហើយអត្រាបង្កកំណើតជាមធ្យមគឺ៧៣ ភាគរយ។ ចំណែក អាយុកាលនៃការប្រើប្រាស់របស់មេបា អាចស្ថិតក្នុងចន្លោះពី៦-១២ ខែ ក្រោយពីថ្ងៃ ដែលចាប់ផ្តើមបង្កាត់ពូជដោយគិតអាយុជាមធ្យមគឺ៩ខែ ។

យើងអាចចិញ្ចឹមក្រួចញី ដើម្បីយកស៊ុតបន្តទៅទៀតបានមួយរយៈ ឬក៏ធ្វើការ





ស៊ុតក្រួចប្រមូលបានពីមេបា អាយុ៧០-១២០ថ្ងៃ

ដកចេញ(ជម្រុះ)ទាំងភេទញី និង ភេទឈ្មោលបញ្ចេញជាក្រួចសាច់ព្រមៗគ្នាក៏បាន។

### ៤.២. ការភ្ញាស់ស៊ុត:

ដោយការប្រើទូភ្ញាស់ស៊ុត ត្រូវមានការជ្រើសរើស រួចបំបែកដោយដាក់នៅលើ ថាសជាថ្នាក់ៗមុនយកចូលទៅកាន់ទូភ្ញាស់ ។ ប្រភេទស៊ុតបង្កកំណើតឱ្យជាកូនជាភេទ ញីច្រើននោះ គឺជាប្រភេទស៊ុតដែលមានសណ្ឋានមូលរលោង ហើយទាល ចំណែកស៊ុត បក្សីដែលមានលក្ខណៈស្រួចហើយវែង គឺជាប្រភេទស៊ុតដែលបង្កកំណើតទៅជាបក្សី ភេទឈ្មោលច្រើន ។

កសិករ ឬអ្នកចិញ្ចឹមភាគច្រើនមិនបានធ្វើការជ្រើសស៊ុត មុននឹងធ្វើការភ្ញាស់ នៅឡើយទេ ពីព្រោះគេយល់ថានាំឱ្យខាតពេលវេលា ។ ចំពោះអត្រាញាស់របស់ស៊ុត អាចមាននៅចន្លោះពី ៦៥-៨០% ហើយជាមធ្យមគឺ ៧២% ។ ក្នុងការភ្ញាស់ស៊ុតនៅ រយៈពេលដំបូងត្រូវមានការបង្វិលស៊ុតចុះឡើងរាល់ថ្ងៃ២-៣ដងក្នុងមួយថ្ងៃ ដោយប្រើ ដៃថ្នមៗ ដើម្បីឱ្យស៊ុតមានចលនារហូតដល់ថ្ងៃទី១៤ ថ្ងៃនៃការភ្ញាស់ទើបបញ្ចប់ការ ត្រឡប់ស៊ុត ដើម្បីឱ្យកូនបក្សីត្រៀមផ្តល់កំណើត ។

ត្រូវធ្វើការសង្កេតមើលឱ្យបានហ្មត់ចត់ពីសភាពប្រែប្រួលរបស់ស៊ុតកុំឱ្យស្ងួត



ការរៀបស៊ុតក្រួចចូលក្នុងថាស



ការដាក់ស៊ុតចូលក្នុងទូភ្ញាស់

ពេក ។ ប្រសិនបើស៊ុតបក្សីស្ងួតពេក យើងត្រូវធ្វើការបាញ់ស្រ្តាយ៍ ឬប្រោះទឹកជាចំហាយផ្សេងក្រួចទៅលើស៊ុតតែមិនត្រូវឱ្យច្រើនពេកទេ។

ការដែលបាញ់ជាចំហាយទឹកនេះ គឺដើម្បីការពារមិនឱ្យស្បែកកូនបក្សីស្អិតជាប់សំបកស៊ុតនៅពេលដែលកូនបម្រាស់ចេញពីសំបក( មិនដូច្នោះទេបណ្ដាលឱ្យកូនស្អិតជាប់សំបកអាចងាប់បាន )

កូនក្រួចអាចញាស់ចេញពីស៊ុតក្នុងថ្ងៃទី១៦-១៧។ ក្រោយពីញាស់ចេញជារូបរាង្គត្រូវឱ្យវានៅក្នុងទូភ្ញាស់បន្តប្រមាណមួយថ្ងៃទៀត រហូតធ្វើឱ្យកូនបក្សីរឹងមាំល្អទើបយកចេញមកចិញ្ចឹមក្នុងទ្រុងផ្សេងៗទៀត។

## ៥. ការកម្តៅកូនបក្សី៖

ក្រោយពីនាំកូនក្រួចចេញពីទូភ្ញាស់ហើយត្រូវនាំទៅចិញ្ចឹមបន្តក្នុងទ្រុងកម្ដៅ។ រយៈពេលកម្ដៅកូនក្រួចស្ថិតក្នុងចន្លោះពី ១០-២១ ថ្ងៃ ក្រោមសីតុណ្ហភាពរបស់ធាតុអាកាសគឺប្រសិនបើជួបអាកាសធាតុត្រជាក់រងារគឺត្រូវប្រើពេលវេលាឱ្យយូរបន្តិច។

ឧទាហរណ៍: កម្ដៅកូនបក្សីត្រូវប្រើអំពូលភ្លើងខ្នាត ៤០-៦០ វ៉ាត់ ព្យួរឱ្យខ្ពស់ពីទ្រុងប្រមាណ១ហ្វូត (អំពូលភ្លើងមួយសម្រាប់បក្សី១០០ក្បាល)។ ចំនួនអំពូលភ្លើងឬសេចក្ដីត្រូវការភាពកក់ក្ដៅរបស់កូនបក្សីជាកត្តាសំខាន់ ដោយកូនបក្សីអាចបង្ហាញ

នូវអាការៈតមស្នងចំពោះមជ្ឈដ្ឋានជុំវិញដូចជាៈ

ប្រសិនបើកូនបក្សីដេកត្រសុលគរលើគ្នាច្រើនក្នុងបរិវេណតែមួយ គឺបង្ហាញថាកូនបក្សីរងារខ្លាំងត្រូវបន្ថែមអំពូលភ្លើងទៀត ប្រសិនបើរត់ប្រសេចប្រសាចទៅឈរឆ្ងាយៗពីគ្នាគឺកូនបក្សីក្តៅជ្រុលពេក ។ យើងត្រូវលើកអំពូលភ្លើងឱ្យខ្ពស់បន្តិច ឬបន្ថយចំនួនអំពូលភ្លើងឱ្យតិចជាងមុនក៏បាន ។ បើសិនកូនបក្សីដេក ដើរលេងសប្បាយជុំវិញអំពូលភ្លើងវិញនោះបង្ហាញថាភាពកក់ក្តៅដែលបានផ្តល់ឱ្យនោះគឺគ្រប់គ្រាន់សមល្មមហើយ ។

ភាពកក់ក្តៅដែលកូនបក្សីត្រូវការ



ក្រួចទទួលបានកម្តៅសមស្រប



ក្រួចរងា

### ៨.១. ការថែរក្សា ឬអនុបាលកូនបក្សីៈ

| អាយុ/សប្តាហ៍ | ភាពកក់ក្តៅដែលត្រូវផ្តល់ | |
|---|---|---|
| | អង្សាសេ | ផារិនហៃ |
| ០-១ | ៣៨ | ១០០ |
| ១-២ | ៣៥ | ៩៥ |
| ២-៣ | ៣០ | ៨៥ |

ក្រោយពីធ្វើការកម្តៅកូនបក្សីហើយ ទើបធ្វើការនាំទៅចិញ្ចឹមក្នុងទ្រុងអនុបាលបន្តជាទ្រុងបក្សីជំទង់រហូតដល់អាយុ ៣០-៣៥ ថ្ងៃ ទើបផ្លាស់ចូលទៅទ្រុងបក្សីស៊ុត

ដែលការឱ្យអាហារគឺនៅតែជាអាហារកូនបក្សី (អាចប្រើអាហារកូនមាន់ ឬអាហារថៃលេខ៨១ក៏បាន)។

### ៨.២. ការជ្រើសភេទ និង ការកាត់ចំពុះ:

សត្វក្រួចដែលទើបនឹងកើត គឺមិនអាចកំណត់ពីភេទឱ្យបានច្បាស់លាស់ដោយលក្ខណៈខាងក្រៅបានឡើយគឺរហូតដល់អាយុប្រមាណ ៣-៤ អាទិត្យទើបយើងអាចដឹងពីភាពខុសគ្នារវាងភេទរបស់បក្សីបានយ៉ាងច្បាស់លាស់។

លក្ខណៈរបស់បក្សីឈ្មោល អាចសង្កេតបានដោយសាររោមនៅលើដើមទ្រូងពណ៌ត្នោតលាយក្រហម ឬពណ៌លឿងឆ្លាស់ពណ៌ត្នោតលាយស។ បក្សីឈ្មោលមានអវៈយវៈភេទជាក្រពេញបន្តពូជ ប្រសិនបើប្រើដៃច្របាច់គូទបក្សីនឹងឃើញមានពពុះពណ៌សចេញមក តែភេទញីមិនមានឡើយ ។ ក្រៅពីនេះនៅមានការស្តាប់សម្លេងរងាវ «បូល» ទៀតបក្សីឈ្មោលបូលលឺខ្លាំងរីឯញីវាមិនបូលឡើយ។




ក្រួចឈ្មោល

លក្ខណៈបក្សីញីពណ៌រោមទ្រូងខុសពីបក្សីឈ្មោល បក្សីញីមានចំពុះខ្មៅអុចៗជុំវិញដើមទ្រូង ឬដែលគេនិយាយហៅគ្រប់គ្នាថា «ខ្សែក» ខ្សែកនេះនៅជុំវិញបក្សីញី។ ការជ្រើសរើសភេទរបស់បក្សីមួយភាគធំ ច្រើនធ្វើនៅពេលបក្សីមានអាយុ២០-២១ថ្ងៃ ព្រមទាំងធ្វើការកាត់ចំពុះបក្សីក្នុងពេលជាមួយគ្នានេះដែរ ។




ក្រួចញី

សម្រាប់ការកាត់ ឬដុតចំពុះនេះគឺដើម្បីការពារមិនឱ្យបក្សីចឹកគ្នា និងឱ្យបក្សីស៊ីចំណីបានស្រួល ។




ការកាត់ចំពុះធ្វើឱ្យក្រួចងាយស្រួលស៊ីចំណី

## VI. ជំងឺ និងវិធានការការពារ ព្យាបាល៖

ជំងឺរបស់ក្រួចគឺដូចទៅនឹងជំងឺរបស់មាន់ដែរ តែខុសត្រង់សត្វក្រួចមានភាពធន់នឹងរោគ (ស៊ាំនឹងជំងឺ) ច្រើនជាងមាន់ ។ ជំងឺដែលច្រើនតែជួបប្រទះ និងកើតនៅលើសត្វក្រួចជាញឹកញាប់មានដូចជា:

### ១. ជំងឺញូវកាស:

រោគសញ្ញា: ក្អក កណ្ដាស់ញយៗ មានផ្ដាសាយ ហៀរសំបោរ ប្រព័ន្ធនៃការដកដង្ហើមខូចខាត មានឈាមចេញតាមក្រពះ ពោះវៀន និងបំពង់ខ្យល់ ហើយអត្រានៃការស្លាប់ខ្ពស់ ការផ្ដល់ស៊ុតថយចុះ ជំងឺនេះអាចឆ្លងរាលដាលបានយ៉ាងឆាប់រហ័ស ។



ក្រួចកើតជំងឺញូកាស (Newcastle disease on quail)

**ការការពារ:** ដោយប្រើវ៉ាក់សាំងពេលបក្សីមានអាយុ៤សប្តាហ៍ ដោយបន្តក់ភ្នែកឬច្រមុះប្រើពេល៧-១៤ថ្ងៃក្នុងការបង្កើតភាពស៊ាំនៃជំងឺ។ត្រូវប្រើវ៉ាក់សាំងប្រភេទនេះរាល់៣ខែម្តង ។



ក្រួចកើតជំងឺញូកាស (Newcastle disease on quail)

**ការព្យាបាល:** មិនចាំបាច់ត្រូវមានការរៀបចំផ្នែកសុខាភិបាល ប្រសិនបើមិនធ្វើការព្យាបាល គឺត្រូវបំផ្លាញសាកសពដូចជាដុត ឬកប់ចោលតែម្តង ។

### ២. ជំងឺរលាកពោះវៀនៈ

ជាជំងឺដែលច្រើនកើតឡើងជាញឹកញាប់ទៅលើសត្វក្រួចធ្វើឱ្យខាតបង់ការចិញ្ចឹមយ៉ាងធ្ងន់ធ្ងរ។

**រោគសញ្ញា:** ជារោគដែលឆ្លងរហ័ស សត្វមានអាការៈរាគរូស ត្របកភ្នែកបិតពាក់កណ្តាលសំកុក មិនស៊ីចំណីឡើងកម្តៅ រោមស្អាប់ ហើយបក្សីមានផ្ទុកជំងឺនេះមានអត្រានៃការស្លាប់ពី៥០-១០០% មេរោគអាចឆ្លងតាមទឹកផឹកនិងអាហារ។

**ការការពារៈ** ការការពារដ៏ល្អគឺត្រូវចិញ្ចឹមបក្សីលើទ្រុងសំណាញ់

**ការព្យាបាលៈ** ប្រើថ្នាំព្យាបាលពួក Bracitracin និងពួក Streptomycin។

### ៣. ជំងឺផ្តាសាយៈ

**រោគសញ្ញាៈ** បក្សីមានអាការៈហៀរសំបោរ និងសំកុក

**ការការពារៈ** ត្រូវប្រយ័ត្នបំផុតពីរឿងត្លៀងសាច និងរណ្តៅបង្ហូរទឹក ក្រៅពីនេះ





*ក្រួចកើតជំងឺផ្តាសាយ*

ត្រូវរក្សាអនាម័យទ្រុងឱ្យបានស្អាតដោយអនុវត្តន៍ឱ្យបានជាប់ៗគ្នាពី២-៣ថ្ងៃម្តង

**ការព្យាបាលៈ** ប្រើថ្នាំអង់ទីប៊ីយូទិចពពួក Tetraciclin ឬ Etromycin ប្រើជាប់ៗគ្នាពី៣-៥ថ្ងៃ។

### ៤. ជំងឺ (Coccidiosis) :

**ការការពារៈ** ត្រូវរក្សាអនាម័យទ្រុងឱ្យបានស្អាតជាប្រចាំ និងផ្សំថ្នាំការពារជំងឺនេះក្នុងអាហារបក្សីតូច (ហាមប្រើលើបក្សីធំ)

**ការព្យាបាលៈ** ប្រើថ្នាំលាយក្នុងទឹកឱ្យសត្វផឹកនឹងគួរប្រើថ្នាំដែលមិនមានផលប៉ះពាល់ចំពោះប្រព័ន្ធបន្តពូជ ឬសំបុក្រពង(អូវែ) ដូចជាណេអូមីស៊ីនជាដើម។



ការធ្វើអនាម័យទ្រុង



ការប្រើថ្នាំលាយជាមួយទឹកលាយឱ្យក្រួចផឹក

**៥. ជំងឺអុតៈ**

រោគសញ្ញាៈ មិនសូវមានកម្លាំង បក្សីចុះខ្សោយជាលំដាប់ និងកើតជាកន្ទួលៗស្រដៀង និងការដុះសាច់ហើយរីកដុះដាលនៅលើស្បែកគ្រប់កន្លែងខាងក្រៅរាងកាយ ជាពិសេសគឺកន្លែងដែរគ្មានដុះរោម

ការការពារ និងការព្យាបាលៈ ដោយប្រើវ៉ាក់សាំងការពារជំងឺអុតតែម្តងគត់ពេលកូនបក្សីមានអាយុបាន២០-២៥ថ្ងៃ។

**៦. ជំងឺរលាកបំពង់ខ្យល់ៈ**

រោគសញ្ញាៈ សំកុកមិនស៊ីចំណី ពិបាកដកដង្ហើម ហូរទឹកភ្នែក ហូរសំបោរ ឈឺពោះ មានចំណុចក្រហម( ឈាម ) ឈឺបំពង់ខ្យល់ និងអាចឆ្លងទៅជារលាកក្រលៀន។ ជំងឺនេះមិនអាចបង្ហាញពីអាការៈខាងផ្លូវប្រសាទឡើយ ការពងខុសប្រក្រតីឬក៏បញ្ឈប់នូវការពងទាំងស្រុង។

ការការពារៈ ប្រើវ៉ាក់សាំងការពារពេលបក្សីនៅតូច

ការព្យាបាលៈ ប្រើពួកអង់ទីប៊ីយូទិចក្នុងការព្យាបាល។

**៧. ជំងឺបណ្តាលពីព្រូនៈ**

រោគសញ្ញាៈ ព្រូនខាងក្នុងគ្រប់ប្រភេទដែលមានទំហំតូច យើងមិនអាចមើលឃើញដោយភ្នែកទទេបានទេ បក្សីដែលផ្ទុកព្រូនមិនសូវបង្ហាញសញ្ញាខុសប្រក្រតីក្នុងរយៈពេលដំបូងឡើយ តែក្រោយមកខ្លួនបក្សីអាចចុះស្គមជាលំដាប់ អស់កម្លាំងខ្លាំង

ហើយធ្វើឱ្យមានអត្រាស្លាប់ខ្ពស់ជាពិសេសនៅលើបក្សីតូច ចំពោះបក្សីពងភាគរយនៃការផ្តល់ស៊ុតនឹងមានការថយចុះ ។

ព្រូនដែលច្រើនជួបប្រទះលើក្រួចគឺៈ ពពួក Crop worms ឬ Thread worms ហើយឆ្លងតគ្នាតាមលាមកសត្វដែលផ្ទុកពងព្រូនធ្លាក់ចុះក្នុងទ្រុងចិញ្ចឹម។

## V. ការប្រមូលផលៈ

ក្រួចញីចាប់ផ្តើមពងនៅពេលវាមានអាយុចំនួន ៧ សប្តាហ៍ (៤៩ថ្ងៃ) វាអាចពងបានរហូតដល់១៨០ពង ក្នុងមួយរដូវកាលនៃអាយុរបស់វា។ នៅពេលមានអាយុ ៨ សប្តាហ៍ចំនួនពងរបស់វានៅរក្សាត្រឹមកម្រិតហាសិបភាគរយ និងបន្តបែបនេះរហូតទៅ។ ពងរបស់ក្រួចមានទម្ងន់ប្រមាណ ៩ទៅ១០ក្រាមតែប៉ុណ្ណេះ យើងអាចប្រមូលពងបានចំនួនពីរដងក្នុងមួយថ្ងៃទីផ្សារក្នុងប្រទេសកម្ពុជាពងក្រួចមួយអាចលក់បានពី ២០០-



ការប្រមូលផលក្រួច

ទៅ ៣០០ រៀល កូនក្រួចអាយុ១៥ថ្ងៃ អាចលក់បានតម្លៃ ១៣០០ ទៅ ១៥០០រៀល ក្នុងមួយក្បាលសម្រាប់អ្នកទិញយកទៅចិញ្ចឹម មេក្រួចពងអាយុ ៧ សប្តាហ៍អាចលក់បានតម្លៃ ២៥០០ ទៅ ៣០០០ រៀលក្នុងមួយក្បាល ក្រួចសាច់លក់ក្នុងទីផ្សារបានតម្លៃ ២០០០ -២៣០០រៀល ក្រួចសាច់ធ្វើស្អាតរួចហើយ អាចលក់បានតម្លៃ ២៣០០ ទៅ ៣០០០រៀល តម្លៃប្រកួតប្រជែងក្នុងទីផ្សារគឺ ២២០០ រៀល។

## ឯកសារយោង៖


1. បច្ចេកទេសចិញ្ចឹមក្រួច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ដើម្បីសន្តិសុខស្បៀង និងអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព
2. បច្ចេកទេសចិញ្ចឹមសត្វក្រួច និងការផ្សំចំណីដោយខ្លួនឯង
3. ឯកសារផ្សព្វផ្សាយការចិញ្ចឹមក្រួច Heifer Project International -Cambodia
4. ពូជក្រួចទំនើប រៀបរៀងដោយ បណ្ឌិត មាយ ប្រមូល, ឆ្នាំ២០២០
5. បច្ចេកទេសចិញ្ចឹមក្រួចឱ្យបានផលខ្ពស់, បណ្ឌិត មាយ ប្រមូល, ឆ្នាំ២០២០
6. Feeding Quail, by Mississippi State University, 2019
7. How to build a quail Habitat, by Ryan Corrigan, ete 2019.
8. How to feed quail, by Amy Harrison, 2020
9. Quail Feeding Quide for beginners, 2020
10. Raising quail for Meat and Eggs, by Blake culver, 2020.
11. Raising quail for commercial use, Mississippi State University.






ក្រុមការងារចងក្រង កូនសៀវភៅណែនាំ ស្តីពីបច្ចេកទេសចិញ្ចឹមក្រួច សូមការអធ្យាស្រ័យពីប្រិយមិត្តអ្នកអានផងដែរ បើសិនជាការបោះពុម្ពផ្សាយកូនសៀវភៅបច្ចេកទសកសិកម្ម ជាលើកទី១នេះ នៅមានការខ្វះចន្លោះ ផ្នែកបច្ចេកទេស រូបភាព និងអក្ខរាវិរុទ្ធ រាល់ការខ្វះខាតទាំងនេះ ក្រុមការងារយើងខ្ញុំ សង្ឃឹមថា នឹងទទួលបាននូវការជួយកែលម្អបំពេញបន្ថែមពីសំណាក់ប្រិយ៍មិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន រាល់ការ កែលម្អទាំងអស់នោះ ក្រុមការងារយើងខ្ញុំ នឹងយកទៅចងក្រងសម្រាប់ការបោះពុម្ពផ្សាយជាលើកទី២បន្តទៀត។ សូមអរគុណ!










**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចម្ការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : ០១៧ ៩០៩ ៣៤៥/០១២ ៣២៥ ៧១០

**គេហទំព័រ** : www.khmeragri.info/www.deaff.maff.gov.kh